# រួមគ្នាកសាងពិភពលោកឲ្យកាន់តែល្អបវរ

## ឯកឧត្តម ស៊ី ជីន ភីង

អគ្គលេខាធិការនៃគណៈកម្មាធិការកណ្តាលគណបក្សកុម្មុយនិស្តចិននិងជាប្រធានាធិបតេយ្យនៃសាធារណៈរដ្ឋប្រជាមានិតចិន

ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ ទីក្រុងប៉េ កាំងប្រទេសចិន

-សូមគោរពអ្នកដឹកនាំបក្សគ្រប់រូបនៃបណ្តាប្រទេសនានា

-ឯកឧត្តម លោកជំទាវ លោក លោកស្រី

ជម្រាបសួរ! ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង ដោយមានឱកាសចូលរួមក្នុងកិច្ចប្រជុំជាន់ខ្ពស់នៃបក្សកុម្មុយនិស្តចិនសន្ទនាជាមួយគណបក្សនយោបាយនៅលើពិភពលោក រួមជាមួយអ្នកដឹកនាំគណបក្ស និងអង្គការនយោបាយដែលមកពីបណ្តាប្រទេសនានាលើពិភពលោក។ នៅពេលជិតចូលឆ្នាំថ្មី លោកអ្នកទាំងអស់ពិតជាជាប់រវល់ខ្លាំងណាស់ តែបានឆ្លៀតពេលដ៏មានតម្លៃជួបជុំគ្នានៅក្រុងប៉េកាំង ដើម្បីពិគ្រោះ ពិភាក្សាអំពីកិច្ចសហប្រតិបត្តិការជាមួយគ្នា។ នេះបានបង្ហាញពីការយកចិត្តទុកដាក់របស់លោកអ្នកចំពោះការអភិវឌ្ឍន៍របស់មនុស្សជាតិ និងអនាគតរបស់ពិភពលោក។

ខ្ញុំសូមយកឱកាសនេះតាងនាមគណបក្សកុម្មុយនិស្តចិន និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ថ្លែងនូវការស្វាគមន៍យ៉ាងរាក់ទាក់កក់ក្តៅចំពោះមិត្តល្អមកពីបណ្តាប្រទេសនានា ដែលបានធ្វើដំណើរយ៉ាងឆ្ងាយដើម្បីចូលរួមក្នុងកិច្ចប្រជុំនេះ។ នៅពេលរៀបចំសមាជបក្សកុម្មុយនិស្តចិនលើកទី ១៩ យើងខ្ញុំបានទទួលនូវលិខិតអបអរសាទរពីអ្នកដឹកនាំ និងគណបក្សឬអង្គការនយោបាយជាច្រើន ខ្ញុំសូមយកឱកាសនេះថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកអ្នក!

សមាជបក្សកុម្មុយនិស្តចិនលើកទី ១៩ បានកសាងផែនទីបង្ហាញផ្លូវនៃការអភិវឌ្ឍន៍របស់ប្រទេសចិន ដែលគ្របដណ្តប់លើដំណាក់កាលគិតចាប់តាំងពីពេលនេះរហូតដល់ពាក់កណ្តាលសតវត្សរ៍នេះ និងបានប្រកាសជាសាធារណៈនូវក្តីសង្ឃឹមដ៏ស្មោះស្ម័គ្ររបស់ភាគីចិនអំពីការរួមសហការគ្នាជាមួយភាគីនានាក្នុងការកសាងសហគមន៍រួមវាសនាមនុស្សជាតិ។ គណបក្សនយោបាយដើរតួនាទីសំខាន់ក្នុងប្រព័ន្ធនយោបាយនៃប្រទេសមួយ ហើយក៏ជាកម្លាំងសំខាន់សម្រាប់ជំរុញការអភិវឌ្ឍន៍នៃអរិយធម៌មនុស្សជាតិ។ ភ្ញៀវកិត្តិយសដែលចូលរួមក្នុងកិច្ចប្រជុំនេះជាអ្នកដឹកនាំនៃគណបក្ស និងអង្គការនយោបាយចំនួនជិត ៣០០ ក្នុងបណ្តាប្រទេសនានាលើពិភពលោក ខ្ញុំមានភាពរីករាយក្នុងការចែករំលែកគ្នាអំពីទស្សនៈរបស់ខ្ញុំជាមួយលោកអ្នក។

-ឯកឧត្តម លោកជំទាវ លោក លោកស្រី

តាំងពីសម័យបុរាណរហូតមកដល់ពេលបច្ចុប្បន្ន ការស្វែងរកជីវភាពរស់នៅដ៏ល្អបវរគឺជាសុបិនរបស់មនុស្សជាតិ ដែលខិតខំប្រឹងប្រែងដើម្បីសម្រេចបានជារៀងរហូតមក។ ក្នុងប្រវត្តិសាស្ត្រអភិវឌ្ឍអរិយធម៌ដែលមានរយៈកាលរាប់ពាន់ឆ្នាំនោះ មនុស្សជាតិបានទទួលនូវសមិទ្ធផលអរិយធម៌ដ៏ត្រចះត្រចង់ តែសង្គ្រាមនិងការវិវាទតែងតែកើតមានឡើងមិនដែលខាន ព្រមទាំងគ្រោះមហន្តរាយធម្មជាតិ និងជំងឺអាសន្នរោគគ្រប់ប្រភេទបានធ្វើឱ្យមនុស្សជាតិរងគ្រោះរាប់មិនអស់ និងមានការបាត់បង់ដ៏ច្រើន។ ថ្ងៃនេះ "បណ្តាញអ៊ីនធើណេត" "Big Data" "Cloud Computing" "Quantum Satellite" និង "Artificial Intelligence" បានទទួលនូវការរីកចម្រើនយ៉ាងឆាប់រហ័ស

ចំណែកជីវភាពរស់នៅរបស់មនុស្សជាតិមានទំនាក់ទំនងស្អិតល្មួតដែលមិនធ្លាប់មានកាលពីមុន។ ជាមួយគ្នានោះ មនុស្សជាតិកំពុងប្រឈមនឹងបញ្ហាដែលមានលក្ខណៈពិភពលោក ហើយមានចំនួនដ៏ច្រើន មានទ្រង់ទ្រាយយ៉ាងធំ និងមានកម្រិតយ៉ាងស៊ីជម្រៅ ដែលមិនធ្លាប់ជួបកាលពីមុន។ អនាគត និងជោគវាសនារបស់ប្រជាជននៃបណ្តាប្រទេសនានាបានត្រូវតភ្ជាប់នឹងគ្នាកាន់តែស្អិតល្មួត។

ប្រឈមនឹងសភាពការណ៍បែបនេះ មនុស្សជាតិអាចមានជម្រើសចំនួនពីរ។ ជម្រើសមួយគឺ ពួកគេប្រកួតប្រជែងគ្នាក្នុងគោលបំណងអាក្រក់ រហូតដល់ច្បាំងគ្នា ដើម្បីដណ្តើមយកអំណាចនិងសិទ្ធិរបស់ខ្លួន នេះប្រហែលនឹងអាចនាំមកនូវវិបត្តិដូចគ្រោះមហន្តរាយ។ ជម្រើសមួយទៀតគឺ ពួកគេដើរឆ្ពោះទៅមុខស្របតាមនិន្នាការអភិវឌ្ឍន៍នៃយុគសម័យ រួមសាមគ្គីគ្នាជាធ្លុងមួយដើម្បីដោះស្រាយបញ្ហាប្រឈមផ្សេងៗ ធ្វើកិច្ចសហប្រតិបត្តិការនៅទូទាំងពិភពលោក នេះនឹងអាចបង្កលក្ខណៈងាយស្រួលសម្រាប់កសាងសហគមន៍រួមវាសនាមនុស្សជាតិ។ យើងទាំងអស់គ្នាត្រូវក្តាប់ជាប់នូវកាលានុវត្តភាពជាប្រវត្តិសាស្ត្រ ជ្រើសយកជម្រើសដ៏ត្រឹមត្រូវ និងរួមគ្នាកសាងអនាគតកាន់តែភ្លឺស្វាងរបស់មនុស្សជាតិទាំងមូល។

ជនជាតិចិនមានប្រវត្តិសាស្ត្រដ៏យូរលង់ និងអរិយធម៌ដ៏ត្រចះត្រចង់ តែក្នុងសម័យទំនើបប្រទេសចិនធ្លាប់ជួបប្រទះនឹងក្តីលំបាកដ៏ច្រើន។ ប្រជាជនចិនមិនដែលសុំចុះចាញ់ចំពោះវាសនានោះទេ បែរជាប្រយុទ្ធតស៊ូ និងខិតខំឧស្សាហ៍ព្យាយាមជាប់រហូត ហើយបានត្រួសត្រាយផ្លូវធំទូលាយមួយខ្សែ ដើម្បីដើរឆ្ពោះទៅកាន់ទិសដៅនៃការស្តារភាពរុងរឿងដ៏មហិមារបស់ជនជាតិចិន។ បើរំលឹកឡើងវិញនូវប្រវត្តិសាស្ត្រ អ្វីដែលទ្រទ្រង់ឱ្យជនជាតិចិនដែលមានប្រវត្តិសាស្ត្រដ៏យូរអង្វែង និងទ្រទ្រង់ឱ្យអរិធម៌ចិនដែលមានអាយុកាលជាង ៥០០០ ឆ្នាំវិវឌ្ឍដល់ពេលបច្ចុប្បន្ននោះគឺ ហ្សែនវប្បធម៌ដែលបានចាក់ឫសយ៉ាងស៊ីជម្រៅក្នុងសាច់សាលោហិតរបស់ជនជាតិចិន។ តាំងពីសម័យបុរាណរៀងមក ជនជាតិចិនតែងតែគាំទ្រនិងប្រកាន់ខ្ជាប់នូវទស្សនៈ “គ្រួសារតែមួយក្រោមមេឃ” ហើយផ្តួចផ្តើមឱ្យរាប់អានជាមួយអ្វីៗទាំងអស់ គ្រប់ប្រទេសចុះសម្រុងគ្នា គ្រប់ជនជាតិរាប់អានគ្នាដូចបងប្អូន ព្រមទាំងមានក្តីសង្ឃឹមដ៏ល្អបវរដើម្បីកសាងពិភពលោកដែលប្រកបដោយសីលធម៌ និងសុខដុមរមនា។ យើងខ្ញុំយល់ឃើញថា ទោះបីជាប្រទេសផ្សេងៗលើពិភពលោកមានការខ្វែងគំនិតគ្នា ឬជំទាស់នឹងគ្នា ហើយក៏មិនអាចជៀសផុតពីការប៉ះទង្គិចខ្លះៗទេ តែប្រជាជននៃបណ្តាប្រទេសនានាលើពិភពលោកកំពុងរួមរស់នៅជាមួយគ្នា ក្រោមមេឃខៀវតែមួយ ហើយមានស្រុកកំណើតរួមតែមួយ ដូច្នេះ យើងទាំងអស់គ្នាគឺជាគ្រួសារតែមួយ។ ប្រជាជននៃបណ្តាប្រទេសនានាត្រូវប្រកាន់ខ្ជាប់នូវទស្សនៈ “គ្រួសារតែមួយក្រោមមេឃ” លាតដៃដើម្បីឱបគ្នា បង្កើនការយោគយល់គ្នា ស្វែងរកចំណុចឯកភាពគ្នា និងទទួលស្គាល់ចំណុចខុសគ្នា រួមគ្នាខិតខំប្រឹងប្រែងដើម្បីស្ថាបនាសហគមន៍រួមវាសនាមនុស្សជាតិ។

នៅឆ្នាំ ២០១៣ ខ្ញុំបានលើកឡើងជាលើកដំបូងនូវគំនិតផ្តួចផ្តើមអំពីការស្ថាបនាសហគមន៍រួមវាសនាមនុស្សជាតិ។ ខ្ញុំមានភាពសប្បាយរីករាយដែលបានឃើញថា កិច្ចសហប្រតិបត្តិការមិត្តភាពរវាងប្រទេសចិននិងបណ្តាប្រទេសនានាបានត្រូវពង្រឹង និងពង្រីកឥតឈប់ឈរ ចំណែកទស្សនៈអំពីការបង្កើតសហគមន៍រួមវាសនាមនុស្សជាតិបានទទួលនូវការគាំទ្រ និងការយល់ព្រមពីប្រជាជនកាន់តែច្រើន។ គំនិតផ្តួចផ្តើមនេះកំពុងប្រែក្លាយពីទស្សនៈមួយទៅជាសកម្មភាពអនុវត្តជាក់ស្តែង។

ខ្ញុំលើកឡើងនូវគំនិតផ្តួចផ្តើមអំពីការស្ថាបនា “ខ្សែក្រវាត់មួយ និងផ្លូវមួយ” គឺដើម្បីជំរុញការអនុវត្តតាមទស្សនៈអំពីការស្ថាបនាសហគមន៍រួមវាសនាមនុស្សជាតិ។ ក្នុងរយៈពេល ៤ ឆ្នាំកន្លងទៅនោះ ការរួមគ្នាស្ថាបនា “ខ្សែក្រវាត់មួយ

និងផ្លូវមួយ” បានក្លាយទៅជាវេទិកាសហប្រតិបត្តិការដ៏ធំសម្បើមសម្រាប់ជំរុញការអភិវឌ្ឍន៍រួមរបស់ប្រទេសពាក់ព័ន្ធផ្សេងៗ។ ស្ទឹងតូចៗប្រសព្វគ្នាទៅជាមហាសមុទ្រដ៏ធំល្វឹងល្វើយ
ពន្លឺផ្កាយនីមួយៗផ្តុំគ្នាបំភ្លឺលំហអវកាសឱ្យមានភាពភ្លឺចិញ្ចាច។ ខ្ញុំជឿជាក់ថា
ឱ្យតែភាគីនានាប្រកាន់ខ្ជាប់នូវទស្សនៈអំពីការស្ថាបនាសហគមន៍រួមវាសនាមនុស្សជាតិ
ហើយរួមគ្នាកំណត់ផែនការអភិវឌ្ឍន៍ រួមគ្នាជំរុញការអនុវត្តជាក់ស្តែង ខិតខំប្រឹងប្រែងជាបន្តបន្ទាប់
និងឧស្សាហ៍ព្យាយាមមិនចេះនឿយហត់
គោលដៅនៃការស្ថាបនាសហគមន៍រួមវាសនាមនុស្សជាតិមុខជានឹងអាចត្រូវសម្រេចជាមិនខាន។

-ឯកឧត្តម លោកជំទាវ លោក លោកស្រី

ពាក្យថា “សហគមន៍រួមវាសនាមនុស្សជាតិ” ពោលគឺ អនាគត
និងជោគវាសនារបស់គ្រប់ជនជាតិ និងគ្រប់ប្រទេសត្រូវតភ្ជាប់នឹងគ្នាយ៉ាងស្អិតល្មួត។
យើងត្រូវរួមសុខទុក្ខជាមួយគ្នា រួមសហការគ្នា ខិតខំប្រឹងប្រែងដើម្បីកសាងភពផែនដី
ដែលជាស្រុកកំណើតរួមរបស់យើងទាំងអស់គ្នា
ឱ្យទៅជាគ្រួសារដ៏ធំមួយដែលប្រកបទៅដោយសុខដុមរមនា
ហើយប្រែក្លាយក្តីសង្ឃឹមអំពីជីវភាពរស់នៅដ៏ល្អបវររបស់ប្រជាជននៃបណ្តាប្រទេសនានាទៅជាភាពពិតប្រាកដ។

យើងត្រូវខិតខំកសាងពិភពលោកមួយ ដែលនៅឆ្ងាយពីអារម្មណ៍ភ័យខ្លាច
និងមានសន្តិភាពទូទៅ។ បើសម្លឹងមើលទៅដំណើរវិវឌ្ឍន៍របស់អរិយធម៌មនុស្សជាតិ
ក្នុងអំឡុងពេលរាប់រយរាប់ពាន់ឆ្នាំកន្លងទៅនោះ
ទោះជាមនុស្សជាតិតែងតែសង្ឃឹមថានឹងអាចទទួលបាននូវសន្តិភាពជានិច្ចកាលក៏ដោយ
ក៏ប៉ុន្តែសង្គ្រាមមិនដែលនៅឆ្ងាយពីយើងទេ
ហើយមនុស្សជាតិតែងតែប្រឈមនឹងការគំរាមកំហែងពីភ្លើងសង្គ្រាម។
មនុស្សជាតិទាំងមូលរួមរស់នៅជាមួយគ្នាលើភពផែនដីតែមួយ
ការគាំពារសន្តិសុខនៃប្រទេសមួយមិនអាចទៅបំផ្លាញសន្តិសុខនៃប្រទេសផ្សេងៗទៀតនោះទេ
ចំណែកការគំរាមកំហែងរបស់ប្រទេសគេក៏អាចក្លាយទៅជាបញ្ហាប្រឈមរបស់ប្រទេសខ្លួនដែរ។
នៅពេលប្រឈមនឹងការគំរាមកំហែងផ្នែកសន្តិសុខ ដែលមានស្ថានភាពកាន់តែស្មុគស្មាញ
និងមានលក្ខណៈជាប្រព័ន្ធ យើងមិនអាចពឹងលើកម្លាំងតែម្នាក់ឯងបានទេ
ហើយក៏មិនអាចពឹងផ្អែកតែលើអំពើហិង្សានោះទេ។
យើងទាំងអស់គ្នាត្រូវតែប្រកាន់ខ្ជាប់នូវទស្សនៈសន្តិសុខថ្មី ដែលមានលក្ខណៈជារួម មានភាពចម្រុះ
ផ្តោតសំខាន់លើកិច្ចសហប្រតិបត្តិការ និងមានលក្ខណៈជានិរន្តរភាព
ដើម្បីបង្កើតជានិម្មាបនកម្មសន្តិសុខ ដែលមានយុត្តិធម៌ រួមគ្នាស្ថាបនា និងចែករំលែកគ្នា
ព្រមទាំងរួមសហការគ្នាក្នុងការបំបាត់កត្តាដែលអាចបណ្តាលឱ្យកើតមានសង្គ្រាម
រួមគ្នាសង្គ្រោះជីវិតរបស់មហាជនដែលរងគ្រោះពីកាំភ្លើងធំ
រួមគ្នាថែរក្សាការពារស្ត្រីនិងកុមារដែលរងគ្រោះពីភ្លើងសង្គ្រាម
ធ្វើឱ្យពន្លឺរស្មីសន្តិភាពចែងចាំងលើភពផែនដីយើង
និងធ្វើឱ្យមនុស្សជាតិទាំងមូលទទួលបានជីវភាពរស់នៅប្រកបដោយសុខដុមរមនា។

យើងត្រូវខិតខំកសាងពិភពលោកមួយ
ដែលនៅឆ្ងាយពីភាពក្រីក្រនិងមានភាពរុងរឿងរួមគ្នា ។ នៅពភិពលោកនាបច្ចុប្បន្ន កំរិតបច្ចេកទេសសម្ភារៈបានរីកចំរើនដល់ដំណាក់កាលមួយដែលបុព្វបុរសពុំដែលស្រមៃដល់ដែរ ប៉ុន្តែការអភិវឌ្ឍនអតុល្យភាពនិងមិនពេញលេញនៅជាបញ្ហាទូទៅមួយ គម្លាតអភិវឌ្ឍន៍រវាងភាគខាងត្បូងនិងភាគខាងជើងនៅតែឆ្ងាយពីគ្នា ភាពក្រីក្រនិងភាពស្រេកឃ្លាននៅតែធ្ងន់ធ្ងរ ចន្លោះឌីជីថលថ្មីកំពុងកើតឡើង ប្រជាជននៅប្រទេសជាច្រើនលើពិភពលោកបានជួបភាពលំបាកសំរាប់ជីវភាពរស់នៅ ។ ប្រសិនបើអនុវត្តនូវតក្កវិជ្ជាចាស់មួយដែលអ្នកចាញ់ខ្ញុំឈ្នះ អ្នកឈ្នះយកទាំងអស់ ប្រសិនបើប្រើរបៀបធ្វើចាស់មួយដែលមានការក្លែងបន្លំឬប្រវញ្ចន៍គ្នាទៅវិញទៅមក ទម្លាក់ភាពលំបាកនិងគ្រោះថ្នាក់ទៅអ្នកជិតខាង នេះនឹងបណ្តាលឲ្យបិទទ្វាររបស់អ្នកដទៃ ក៏បានរាំងផ្លូវរបស់ខ្លួនដែរ បំផ្លិចបំផ្លាញឬសគល់អភិវឌ្ឍន៍របស់ខ្លួន ធ្វើឲ្យខូចអនាគតសំរាប់មនុស្សជាតិទាំងមូល ។ យើងគួរតែប្រកាន់ខ្ជាប់នូវគំនិតមួយដែលអ្នកល្អ ខ្ញុំល្អ អ្នកទាំងអស់គ្នាល្អជាមួយគ្នា ជំរុញសកលភាវូបនីយកម្មផ្នែកសេដ្ឋកិច្ចប្រកបដោយការបើកចំហការបញ្ចូលគ្នា ភាពអនុគ្រោះទូទៅ តុល្យភាពនិងឈ្នះរួមគ្នា បង្កលក្ខខណ្ឌដ៏ល្អមួយសំរាប់អភិវឌ្ឍន៍រួម

គ្នារបស់មនុស្សជាតិទាំងមូល រួមគ្នាជំរុញអភិវឌ្ឍន៍និងភាពរុងរឿងនៃបណ្តាប្រទេសលើពិភពលោក រួមគ្នាលុបបំបាត់នូវភាពក្រីក្រនិងថយក្រោយពីគេដែលប្រជាជននៅប្រទេសជាច្រើននៅតែបានជួបប្រទះ រួមគ្នាផ្តល់ជីវភាពដ៏ល្អដែលមិនបាច់ព្រួយបារម្ភពីសម្លៀកបំពាក់និងអាហារសំរាប់កុមារទូទាំងពិភពលោក ដើម្បីឲ្យផលប្រយោជន៍ពីអភិវឌ្ឍន៍ត្រូវបានចែករំលែកដោយបណ្តាប្រទេសលើពិភពលោក ឲ្យប្រជាជនគ្រប់រូបនឹងមានជីវភាពធូរធាហើយទទួលបានសុខសន្តិភាព ។

យើងត្រូវខិតខំកសាងពិភពលោកមួយ ដែលនៅឆ្ងាយពីការបិទទ្វារនិងមានការបើកចំហនិងការបញ្ចូលគ្នា ។ មានពាក្យសុភាសិតចិនមួយថា វត្ថុធាតុគ្រប់យ៉ាងបានរីកលូតលាស់រួមគ្នាពុំដែលខូចគ្នាទេ ព្រះអាទិត្យនិងព្រះច័ន្ទបានដំណើការតាមគន្លងរៀងៗខ្លួន រដូវទាំង៤បានផ្លាស់ប្តូរគ្នាតាមក្បួនធម្មជាតិពុំដែលផ្ទុយពីគ្នា ។ ភាពរុងរឿងរបស់អរិយធម៌ ការរីកចំរើនរបស់មនុស្សជាតិ មិនអាចផ្តាច់ពីគោលការណ៍មួយដែលស្វែងរកគោលជំហរួមគ្នា រក្សាទុកមតិយោបល់ខុសគ្នា និង ការបើកចំហនិងដាក់បញ្ចូលគ្នា មិនអាចផ្តាច់ពីការផ្លាស់ប្តូរខាងអរិយធម៌និងការរៀនសូត្រគ្នាទៅវិញទៅមក ។ ប្រវត្តសាស្ត្របានអំពាវនាវឲ្យអរិយធម៌របស់មនុស្សជាតិសំរេចការរីកចំរើនរួមគ្នា អរិយធម៌ខុសគ្នាគួរតែអភិវឌ្ឍន៍ដោយភាពសុខដុមរមនា ហើយជំរុញគ្នាទៅវិញទៅមក ដើម្បីរួមគ្នាផ្តល់កម្លាំងស្មារតីដល់អភិវឌ្ឍន៍មនុស្សជាតិ ។ យើងត្រូវប្រកាន់ខ្ជាប់នូវគំនិតមួយដែលពិភពលោកបានសំបូរទៅដោយពណ៌គ្រប់មុខ អរិយធម៌បានមានរូបរាងគ្រប់បែបយ៉ាង ឲ្យគ្រប់អរិយធម៌ដែលបង្កើតឡើងដោយមនុស្សបញ្ចាំងពន្លឺគ្នាទៅវិញទៅមក គួរគំនូរមួយដ៏ស្អាត រួមគ្នាលុបបំបាត់នូវរបាំងផ្នែកវប្បធម៌ក្នុងជីវិតប្រចាំថ្ងៃ រួមគ្នាទប់ទល់នឹងកំហុសខាងគំនិតដែលបានរារាំងនូវការផ្លាស់ប្តូរចិត្តរបស់មនុស្ស រួមគ្នាកម្ចាត់របាំងផ្នែកស្មារតីដែលរារាំងទំនាក់ទំនងរបស់មនុស្សជាតិ ឲ្យគ្រប់អរិយធម៌បានអភិវឌ្ឍន៍ប្រកបដោយភាពសុខដុមរមនា ឲ្យមនុស្សគ្រប់រូបទទួលបានអត្ថប្រយោជន៍ពីវប្បធម៌ ។

យើងត្រូវខិតខំកសាងពិភពលោកមួយ ដែលទេសភាពធម្មជាតិល្អនិងមានភាពស្រស់ស្អាត ។ ផែនដីជាផ្ទះរួមមួយរបស់មនុស្សជាតិ ក៏ជាផ្ទះតែមួយគត់របស់មនុស្សជាតិនាបច្ចុប្បន្ន ។ ឥឡូវនេះ មានមនុស្សខ្លះកំពុងស្វែងរកផ្ទះថ្មីសំរាប់មនុស្សជាតិក្នុងអាវាកាស ក៏ប៉ុន្តែនេះនៅជាសុបិន្តមួយដែលឆ្ងាយពីយើង ។ នៅអនាគតមួយដែលយើងអាចមើលឃើញ មនុស្សជាតិយើងត្រូវបន្តស្នាក់នៅលើផែនដីនេះ ។ នេះជាការពិតមួយដែលមិនអាចផ្លាស់ប្តូរបានទេ ។  យើងត្រូវរួមគ្នាថែទាំពិភពលោកដែលជាផ្ទះរបស់យើងឲ្យបានល្អ ដើម្បីខ្លួនឯងផងនិងដើម្បីកូនចៅយើងផង ។ យើងត្រូវប្រកាន់ខ្ជាប់នូវគំនិតមួយដែលមនុស្សជាតិនិងធម្មជាតិគួរតែរស់នៅជាមួយគ្នានិងរីកចំរើនរួមគ្នា ត្រូវយកចិត្តទុកដាក់ខ្ពស់ចំពោះបរិស្ថានដូចចំពោះជីវិតមនុស្ស ត្រូវមានការស្ងប់ស្ងែងពីចិត្តចំពោះធម្មជាតិ មានសេចក្តីគោរពចំពោះធម្មជាតិ ធ្វើអ្វីតាមក្បួនធម្មជាតិនិងការពារធម្មជាតិ រួមគ្នាការពារផែនដីដែលមិនអាចជំនួសបានទេ រួមគ្នាឲ្យបួសនានារបស់បរិស្ថានត្រូវបានឆាប់ជា រួមគ្នាកសាងផ្ទះមួយដែលមនុស្សជាតិអាចស្នាក់នៅបាននិងប្រកបដោយភាពសុខដុរមនា ឲ្យធម្មជាតិមានពេលសម្រាកនិងស្តារឡើងវិញ ឲ្យមនុស្សគ្រប់រូបអាចមើលទេសភាពធម្មជាតិដ៏ស្រស់ស្អាត ។

-ឯកឧត្តម លោកជំទាវ លោក លោកស្រី

នាបច្ចុប្បន្ន រចនាសម្ព័ន្ធពិភពលោកកំពុងប្រែប្រួល រចនាសម្ព័ន្ធផ្នែកអភិវឌ្ឍន៍កំពុងប្រែប្រួល គណបក្សនយោបាយនានាត្រូវតែស្របទៅនឹងចរន្តអភិវឌ្ឍន៍របស់សម័យ ក្តាប់នូវនិន្នាការវឌ្ឍនភាពរបស់មនុស្សជាតិ ស្របនឹងក្តីសង្ឃឹមរួមរបស់ប្រជាជន ឲ្យការអភិវឌ្ឍន៍របស់ខ្លួនតភ្ជាប់ជាមួយនឹងការអភិវឌ្ឍន៍របស់ប្រទេស ជនជាតិនិងមនុស្សជាតិយ៉ាងជិតស្និទ ។ យើងត្រូវមានឧត្តមគតិឧត្តង្គឧត្តមក្នុងចិត្ត ហ៊ានទទួលការខុសត្រូវ គិតអំពីប្រទេសខ្លួននិងពិភពលោក គិតអំពីសភាពការណ៍ទូទៅនិងរយៈពេលវែង ទទួលបេសកកម្មនៃសម័យកាលយ៉ាងសកម្ម ។ យើងត្រូវស្វែងយល់ពីជីវភាពរស់នៅរបស់ប្រជាជនឲ្យបានស៊ីជម្រៅបន្ថែមទៀត ឲ្យតំរូវការរបស់ប្រជាជនប្រែក្លាយទៅជាគំនិត គោលបំណងនិងគោលដៅរបស់គណបក្សនយោបាយ រៀបចំផែនការអនុវត្តដែលស្របនឹងភាពជាក់ស្តែង ។ កសាងជោគវាសនារួមតែមួយរបស់មនុស្សជាតិ ត្រូវការចូលរួមរបស់ប្រជាជនពីប្រទេសនានា ។ យើងត្រូវប្រមូលមតិយោបល់រួមរបស់ប្រជាជនដែលជាជនជាតិខុសគ្នា មានជំនឿសាសនាខុសគ្នា មានវប្បធម៌ខុសគ្នានិងមកពីតំបន់ខុសគ្នា ដើម្បីរួមគ្នាសំរេចនូវបុព្វកិច្ចមួយដ៏អស្ចារ្យគឺ កសាងជោគវាសនារួមតែមួយរបស់មនុស្សជាតិ ។

ការសំរេចនូវសុបិន្តដ៏អស្ចារ្យមួយត្រូវការប្រាជ្ញានិងកម្លាំងពីគ្រប់មជ្ឈដ្ឋាន ។ យើងត្រូវប្រមូលគំនិតពីគ្រប់ជ្រោងជ្រុយ គ្រប់ថ្នាក់និងគ្រប់វិស័យ ដកបទពិសោធន៍ពីប្រតិបត្តិការជាក់ស្តែង ស្វែងរកគំនិត ឲ្យគំនិតកាន់តែល្អប្រសើរឡើង ទទួលយកកម្លាំង ។ គណបក្សនយោបាយពីប្រទេសខុសគ្នាត្រូវបង្កើនការជឿទុកចិត្តគ្នាទៅវិញទៅមក បង្កើនទំនាក់ទំនងជាមួយគ្នា ឲ្យកិច្ចសហប្រតិបត្តិការគ្នាកាន់តែជិតស្និទ ឈរលើមូលដ្ឋានរបស់ទំនាក់ទំនងអន្តជាតិបែបថ្មី ដើម្បីស្វែងរកកសាងទំនាក់ទំនងគណបក្សនយោបាយថ្មីដែលស្វែងរកគោលជំហររួមគ្នា រក្សាទុកមតិយោបល់ខុសគ្នា ការគោរពគ្នាទៅវិញទៅមក និងការរៀនសូត្រគ្នាទៅវិញទៅមក កសាងបណ្តាញកិច្ចសហប្រតិបត្តិការនិងទំនាក់ទំនងសំរាប់គណបក្សនយោបាយអន្តរជាតិដែលមានបែបបទជាច្រើននិងថ្នាក់ជាច្រើន ប្រមូលកម្លាំងដ៏ខ្លាំងខ្លាសំរាប់ការកសាងជោគវាសនារួមតែមួយ ។

បើសិនចង់បានបុព្វកិច្ចមួយ យើងគួតែធ្វើការជាមុន បើសិនចង់ត្រួសត្រាយផ្លូវមួយ យើងគួរតែដើរទៅជាមុន ។ ការកសាងជោគវាសនារួមតែមួយជាដំណើរការប្រវត្តិសាស្ត្រមួយ មិនអាចសំរេចបានតែមួយភ្លេត ក៏គ្មាដំណើរការមួយដែលប្រកបដោយភាពរលូនជារៀងរហូត ត្រូវការខិតខំប្រឹងប្រែងរយៈពេលវែង ។ ដើម្បីកសាងជោគវាសនារួមតែមួយ យើងត្រូវខិតខំប្រឹងប្រែងឥតឈប់ឈរ កុំឲ្យបោះបង់ចោលនូវសុបិន្តដោយសារការពិតមានភាពស្មុគស្មាញ កុំឲ្យបោះបង់ចោលការស្វែងរកដោយសារមានចម្ងាយឆ្ងាយពីឧត្តមគតិ ។

-ឯកឧត្តម លោកជំទាវ លោក លោកស្រី

គណបក្សកុម្មុយនិស្តចិនជាគណបក្សមួយដែលពាំនាំសុភមង្គលជូនប្រជាជនចិន ក៏ជាគណបក្សមួយដែលខិតខំប្រឹងប្រែងដើម្បីបុព្វកិច្ចវឌ្ឍនភាពរបស់មនុស្សជាតិដែរ ។ គណបក្សកុម្មុយនិស្តចិនជាគណបក្សនយោបាយធំជាងគេលើពិភពលោក ។ ខ្ញុំធ្លាប់មានប្រសាសន៍ថា ធំត្រូវមានរូបរាងដ៏ធំមួយ ។ អ្វីៗដែលបក្សកុម្មុយនិស្តចិនបានធ្វើ សុទ្ធតែដើម្បីសុភមង្គលរបស់ប្រជាជនចិន ដើម្បីការស្តារឡើងវិញរបស់ជនជាតិចិន ដើម្បីសន្តិភាពនិងអភិវឌ្ឍន៍របស់មនុស្សជាតិ ។ យើងត្រូវចាត់ចែងកិច្ចការខ្លួនឯងឲ្យបានល្អ នេះជាវិភាគទានសំរាប់ការកសាងជោគវាសនារួមតែមួយ ។ យើងក៏ត្រូវបង្កឱកាសអភិវឌ្ឍន៍ឲ្យបានច្រើនបន្ថែមទៀតសំរាប់ពិភពលោកតាមរយៈការជំរុញអភិវឌ្ឍន៍ប្រទេសចិន តាមរយៈស្វែងយល់ក្បួនអភិវឌ្ឍន៍សង្គមនិងមនុស្សជាតិពីប្រតិបត្តិការជាក់ស្តែងរបស់ខ្លួន ហើយនឹងចែករំលែកជាមួយនឹងប្រទេសនានា ។ យើងមិននាំចូលរបបពីបរទេស ក៏មិននាំចេញរបបចិនទៅបរទេស មិនបង្ខំឲ្យប្រទេសផ្សេងៗចម្លងរបៀបធ្វើរបស់ប្រទេសចិន ។ គណបក្សកុម្មុយនិស្តចិននឹងធ្វើចំណុចខ្លះជារៀងរហូតគ្មានការងាករេទេដែលដូចខាងក្រោម៖

ទី១-បន្តរួមចំណែកក្នុងការសុខសន្តិភាពពិភពលោក ។ ជិត១០០ឆ្នាំមុន គណបក្សកុម្មុយន្តិចិន ត្រូវបានបង្កើតឡើងក្នុងសង្គមចិនប្រកបដោយច្របូកច្របល់ តាំងពីទសវត្សរ៏ទី៥០សតវត្ស ទី១៩ ប្រទេសចិនបានធ្លាក់ចូលសោកនាដកម្មដ៏ខ្លោចផ្សា ភារកិច្ចមួយដ៏សំខាន់របស់គណបក្ស
កុម្មុយនិស្តចិននៅពេលបង្កើតឡើងគឺបញ្ចប់សង្គ្រាមរ៉ាំរ៉ៃនិងទុក្ខវេទនារបស់ប្រជាជនចិន ។ ចាប់ពីឆ្នាំ១៩២១ទៅឆ្នាំ១៩៤៩ ដើម្បីសំរេចសន្តិភាព ស្ថិរភាពរបស់ប្រទេសចិននិងសុខុមាលភាពរបស់ប្រជាជនចិន គណបក្សកុម្មុយនិស្តចិនបានបង្រួបបង្រួមដឹកនាំប្រជាជនចិនធ្វើការប្រយុទ្ធដោយប្រដាប់អាវុធអស់រយៈពេល២៨ឆ្នាំ ហើយបានធ្វើពលិកម្មដ៏ធំធេង ។ ហេតុនេះហើយ គណបក្សកុម្មុយនិស្តចិនយល់ដឹងច្បាស់ពីតម្លៃនៃសន្តិភាព ហើយក៏មានការប្តេជ្ញាចិត្តដ៏រឹងមាំដើម្បីពង្រឹងសន្តិភាព ។ ប្រទេសចិននឹងបន្តប្រកាន់យកសនិភាព ការអភិវឌ្ឍ កិច្ចសហប្រតិបត្តិការ ឈ្នះ-ឈ្នះរួមគ្នា តែងតែដើរតាមមាគ៌ាអភិវឌ្ឍដោយសន្តិភាពនិងមិនដែលងាករេចេញពី ការប្តេជ្ញាចិត្តនេះ ជំរុញយ៉ាងសកម្មនូវការបង្កើតទំនាក់ទំនងភាពជាដៃគូទូទាំងពិភពលោក
ចូលរួមដោយសកម្មក្នុងដំណើរការដំណោះស្រាយនយោបាយលើបញ្ហាប្រឈមនិងព្រឹត្តិការណ៍ក្តៅគគុកក្នុងអន្តរជាតិ ។ គិតដល់បច្ចុប្បន្ននេះ ប្រទេសចិនបានបញ្ជូនកងកម្លាំងរក្សាសន្តិភាពមួកខៀវសរុបជាង៣ម៉ឺន៦ពាន់នាក់ ហើយបានក្លាយទៅជាប្រទេសសំខាន់ខាងការបញ្ជូនកម្លាំងរក្សាសន្តិភាពមួកខៀវនិងការផ្តល់ថវិកា ក្នុងសកម្មភាពរក្សាសន្តិភាពនៃអង្គការសហប្រជាជាតិ ។ ក្នុងពេលនេះ កម្លាំងរក្សាសន្តិភាពមួកខៀវរបស់ចិនចំនួនជាង២៥០០នាក់កំពុងបំពេញបេសកកម្មនៅតំបន់បេសកកម្មរក្សាសន្តិភាពចំនួន៨ ដោយមិនខ្លាចការលំបាកនិងគ្រោះថ្នាក់ ហើយបានរួមចំណែកក្នុងការរក្សាសុខសន្តិភាពនៅតំបន់ ទាំងនេះ ។ ប្រទេសចិននឹងចូលរួមយ៉ាងសកម្មក្នុងការកែទម្រង់និងការកសាងប្រព័ន្ធ អភិបាលកិច្ចសកល

យើងនិងជំរុញដំណើរការនៃការបង្កើតបទបញ្ញត្តិអន្តរជាតិឱ្យមាន ភាពយុត្តិធម៌និងសមធម៌ ។ មិនថាប្រទេសចិនអភិវឌ្ឍទៅដល់កម្រិតណា យើងមិនប្រើអនុត្តរភាពឬការប៉ុនប៉ងធ្វើសកម្មភាពពង្រីកទឹកដីជាដាច់ខាត ។ យើងសូមអំពាវនាវគណបក្សនយោបាយប្រទេសនានាទូទាំងពិភពលោកព្រួតដៃគ្នាជាមួយគណបក្សកុម្មុយនិស្តចិន ធ្វើស្ថាបនិក នៃសន្តិភាពពិភពលោក ហើយរួមចំណែកក្នុងការអភិវឌ្ឍសកលលោក និងរក្សាសណ្តាប់ធ្នាប់អន្តរជាតិ ។

ទី២-បន្តរួមចំណែកក្នុងការអភិវឌ្ឍរួមនៃពិភពលោក ។ គណបក្សកុម្មុយនិស្តចិនចេញពីប្រជាជន ហើយទទួលបានការរីកចម្រើនដោយពឹងផ្អែកប្រជាជន មាននមនោសញ្ចេតនាជ្រៅជ្រះជាមួយប្រជាជនជារៀងរហូត ។ គណបក្សកុម្មុយនិស្តចិនមិនគ្រាន់តែមាននមនោសញ្ចេតនាជ្រៅជ្រះជាមួយប្រជាជនចិន ហើយក៏មាននមនោសញ្ចេតនាជ្រៅជ្រះជាមួយប្រជាជនទូទាំងពិភពលោក មិនគ្រាន់តែចង់ផ្តល់ផលប្រយោជន៍ទៅកាន់ប្រជាជនចិន ហើយក៏ចង់ផ្តល់ផលប្រយោជន៍ ទៅកាន់ប្រជាជនទូទាំងពិភពលោក ។ ជាច្រើនឆ្នាំកន្លងមកប្រទេសចិនបានផ្តល់ជំនួយឥតសំណង កម្ចីសម្បទានជាច្រើន ព្រមទាំងការគាំទ្រខាងបច្ចេកទេស ធនធានមនុស្សនិងប្រាជ្ញាសំរាប់ប្រទេសកំពុងអភិវឌ្ឍ បានជួយប្រទេសកំពុងអភិវឌ្ឍធ្វើគម្រោងជាច្រើនដែលអាចផ្តល់ផលយោជន៍សំរាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម និងការកែលម្អជីវភាពរស់នៅរបស់ប្រជាជននៅប្រទេសទាំងនេះ ។ សព្វថ្ងៃនេះ មានអ្នកវិទ្យាសាស្ត្រ វិស្វករ សហគ្រិន អ្នកបច្ចេកទេស គ្រូពេទ គ្រូបង្រៀន បុគ្គលិក និងអ្នកស្ម័គ្រចិត្តចិនរាប់ម៉ឺនរាំបពាន់នាក់កំពុងធ្វើការនៅទឹកដីប្រទេសកំពុងអភិវឌ្ឍជាច្រើន ព្រួតដៃគ្នាជាមួយប្រជាជននៅទីនោះ ជួយពួកគេប្តូរជោគវាសនា ។ យោងតាមផែនការដែលដាក់ចេញនៅមហាសន្និបាតទូទាំងប្រទេសលើកទី១៩គណបក្សកុម្មុយនិស្តចិន ប្រទេសចិននឹងបង្កើតបាននូវសង្គមដែលប្រកបដោយវិបុលភាពគ្រប់សព្វបែបយ៉ាងនៅឆ្នាំ ២០២០ នឹងសំរេចជាទូទៅនូវទំនើបកម្មសង្គមនិយមនៅឆ្នាំ២០៣៥ ហើយនឹងបង្កើតបាននូវប្រទេសសង្គមទំនើបកម្មប្រកបដោយសុខដុមរមនា ប្រជាធិបតេយ្យ ស៊ីវិល័យ ស្រស់ប្រិមប្រិយ៍នៅទសវត្សរ៍ទី៥០សតវត្សទី២១ ។ ប្រការនេះនឹងអាចផ្តល់ផលប្រយោជន៍ទៅកាន់ប្រជាជនចិនក៏ដូចជាប្រជាជនប្រទេសនានានៅលើពិភពលោក ។ យើងសូមអំពាវនាវគណបក្សនយោបាយប្រទេសនានាទូទាំងពិភពលោកព្រួតដៃគ្នាជាមួយគណបក្សកុម្មុយនិស្តចិន ដើម្បីបង្កើតកាលានុវត្តភាពធ្វើកិច្ចសហប្រតិបត្តិការកាន់តែច្រើន សំរាប់ ពិភពលោក ខិតខំជំរុញវិបុលភាពនិងការអភិវឌ្ឍរួមនៃប្រទេសទាំងអស់ទូទាំងពិភពលោក ។

ទី៣-
បន្តរួមចំណែកក្នុងការផ្លាស់ប្តូរនិងការរៀនសូត្រពីគ្នាទៅវិញទៅមករវាងអរិយធម៌ផ្សេងៗគ្នាលើពិភពលោក ។ យើងតែងតែនិយាយថា ថ្មភ្នំផ្សេងទៀតអាចធ្វើត្បូងបាន ។ គណបក្សកុម្មុយនិស្តចិនប្រកាន់ខ្ជាប់ទស្សនៈវិស័យពិភពលោក រៀនសូត្រយ៉ាងសកម្មពីសមិទ្ធិផលអរិយធម៌ដែលប្រជាជនប្រទេសនានាបង្កើត ហើយដកស្រង់និងប្រើប្រាស់ស្របតាមស្ថានភាពជាក់ស្តែងរបស់ប្រទេសចិន ។ លទ្ធិម៉ាក្សគឺជាទ្រឹស្តីពិតនិងវិទ្យាសាស្ត្រដែលគណបក្សកុម្មុយនិស្តចិនរៀនសូត្រពីបរទេស ។ យើងអនុវត្តលទ្ធិម៉ាក្សស្របតាមស្ថានភាពជាក់ស្តែងរបស់ប្រទេសចិន និងបន្តកែសម្រួលលទ្ធិម៉ាក្សឱ្យមានលក្ខណៈពិសេសចិន ទាន់សម័យនិងពេញនិយម ដើម្បីក្លាយទៅជាទ្រឹស្តីវិទ្យាសាស្ត្រ ដែលណែនាំប្រជាជនចិនឆ្ពោះទៅមុខដោយឥតឈប់ឈរក្រោមការដឹកនាំពីគណបក្សកុម្មុយនិស្តចិន ។ គណបក្សកុម្មុយនិស្តចិនប្រកាន់យកទស្សនវិស័យបើកចំហចំពោះ សមិទ្ធិផលអរិយធម៌ដែលប្រជាជនប្រទេសនានាបង្កើត នឹងមានបំណងធ្វើកិច្ចសន្ទនានិងសហប្រតិបត្តិការជាមួយប្រជាជននិងគណបក្សនយោបាយពិភពលោក គាំទ្រប្រជាជនប្រទេសនានាបង្កើនការផ្លាស់ប្តូរក្នុងវិស័យសង្គមស៊ីវិល ។ ៥ឆ្នាំខាងមុខនេះ គណបក្សកុម្មុយនិស្តចិននឹងផ្តល់ឱកាសឱ្យមន្ត្រីគណបក្សនយោបាយបរទេសចំនួន១៥០០០នាក់មកសិក្សា និងបណ្តុះបណ្តាល់នៅប្រទេសចិន ។ យើងសូមអំពាវនាវកិច្ចសន្ទនាជាន់ខ្ពស់រវាងគណបក្សកុម្មុយនិស្តចិននិងបណ្តាគណបក្សនយោបាយពិភពលោកក្លាយទៅជាយន្តការមួយ ដើម្បីផ្តល់វេទិកាជាន់ខ្ពស់ ដែលមានលក្ខណៈទូលំទូលាយនិងឥទ្ធិពលអន្តរជាតិ សំរាប់ធ្វើកិច្ចសន្ទនានយោបាយ ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី

ជាង២០០០ឆ្នាំមុន ទស្សនវិទូចិនសម័យបុរាណខុងជឺមានប្រសាសន៍ថា ធ្វើមិត្តជាមួយមនុស្សបីប្រភេទនឹងមានប្រយោជន៍សំរាប់ខ្លួន គឺ មនុស្សស្មោះត្រង់ មនុស្សមានភាពសុចរិត និងមនុស្សមានចំណេះដឹងច្រើន ។ គណបក្សកុម្មុយនិស្តចិនចង់ធ្វើជាមិត្តរបស់បណ្តាគណបក្សនយោបាយ

ទូទាំងពិភពលោក ។ បច្ចុប្បន្ននេះ គណបក្សកុម្មុយនិស្តចិនរក្សាទំនាក់ទំនងជាប្រចាំជាមួយគណបក្សនយោបាយនិងអង្គការនយោបាយចំនួនជាង៤០០ ក្នុងតំបន់និងប្រទេសជាង១៦០លើពិភពលោក ក្រុមមិត្តរបស់គណបក្សកុម្មុយនិស្តចិនបានពង្រីកធំជាបន្តបន្ទាប់ ។ ដើម្បីឆ្ពោះសំដៅអនាគត គណបក្សកុម្មុយនិស្តចិនមានបំណងបង្កើនការផ្លាស់ប្តូរនិងកិច្ចសហប្រតិបត្តិការជាមួយបណ្តាគណបក្សនយោបាយទូទាំងពិភពលោក ចែករំលែកបទពិសោធន៍អភិបាលកិច្ច ធ្វើការផ្លាស់ប្តូរនិងកិច្ចសន្ទនាទៅវិញទៅមករវាងអរិយធម៌ផ្សេងៗគ្នា បង្កើនការទំនុកចិត្តយុទ្ធសាស្ត្រពីគ្នាទៅវិញទៅមក រួមគ្នាជាមួយប្រជាជនប្រទេសនានាលើពិភពលោក កសាងសហគមន៍នៃអនាគតរួមសំរាប់មនុស្សជាតិនិងពិភពលោកស្រស់ស្អាត ។

នៅចុងបញ្ចប់ ខ្ញុំសូមជូនពរកិច្ចសន្ទនាជាន់ខ្ពស់រវាងគណបក្សកុម្មុយនិស្តចិននិងបណ្តាគណបក្សនយោបាយពិភពលោកទទួលបាននូវលទ្ធផលដ៏ល្អត្រចេះត្រចង់ ។

សូមអរគុណ